# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល"
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.~**

អនុក្រឹត្យនេះសម្រាប់ជំនួសឱ្យអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្ដីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ដោយអនុញ្ញាតឱ្យនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " បង្កើតឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់ សម្រាប់មន្ត្រីរាជការ ប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ។

**មាត្រា ២.~**

ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ត្រូវបានកំណត់ដូចតទៅ ÷

**១-ឯកសណ្ឋាន :**

- **ខោវែង** ចំនួន ២ ពណ៌ពងក្រសា ផលិតអំពីសាច់ក្រណាត់តេហ្គាលឡែន ចង្កេះ ត ថ្នេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបី " ហោប៉ៅខាងក្រោយមួយ ដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរ បង្កប់តាមថ្នេរ " ។
- **អាវ** មានពីរថ្នាក់ :
  - **ថ្នាក់ដឹកនាំនាយកដ្ឋាន ចរិយាល័យ និង សាខា :**

    អាវដៃខ្លីចំនួនពីរ មានពណ៌ និងសាច់ក្រណាត់ដូចខោ កបើក ថ្នេរឌុប ប៉ូលស្វា ជីបចង្កេះ មានហោប៉ៅបួន " ហោប៉ៅពីរខាងលើដេរប៉ះបត់ផ្នត់ កណ្ដាល មានគំរបរាងស្លឹកពោធិ ហោប៉ៅផ្ទោកពីរខាងក្រោម ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។
  - **ថ្នាក់មន្ត្រីប្រតិបត្តិ :**

    អាវដៃវែងមួយ អាវដៃខ្លីមួយ ពណ៌ និងសាច់ក្រណាត់ដូចខោ កឌុប ថ្នេរឌុប ចោះឡេវចុងក ប៉ូលស្វា ហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្ដាល មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ។
- **ខ្សែក្រវាត់** ក ខ្លី ពណ៌ ខ្មៅ ស្រោមជើងខ្មៅ ។
- **មួកកាស្កេត** មាន ៤ ថ្នាក់ :
  - **ថ្នាក់ដឹកនាំនាយកដ្ឋាន :**

    មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចខោ ដែលផ្នែកខាងមុខ លើកណ្ដាប់ វិណ្ណ មានភ្ជាប់រូបព្រះសង្ហពណ៌មាស ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៨ ស.ម បែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហាមានកណ្ដាប់វិណ្ណធ្វើពីក្រណាត់

ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ។ ខាងក្រោមកណ្តាប់វីណ្ណបើកខាងមុខ មានក្បាំងពណ៌ខ្មៅ ។ ផ្នែកខាងមុខ ក្រោមកណ្តាប់វីណ្ណ ដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ខាពណ៌មាស ។ នៅលើក្បាំងមួក មានបាំនក្បាច់ភ្ញីទេសឱ្យនពណ៌មាស ទម្រង់ស្លែងក្របីដល់ជើងមួក ។

• **ថ្នាក់ការិយាល័យ និង ចណ្តាសាខា :**

មានរូបភាព និងម៉ូតដូចថ្នាក់ដឹកនាំនាយកដ្ឋានដែរ តែខុសគ្នា ត្រង់នៅលើក្បាំងមួក មានបាំនក្បាច់ភ្ញីទេសឱ្យន ពណ៌មាស ទម្រង់ស្លែងក្របី ដោយចុងសងខាង ទុកចន្លោះ ៤ ស.ម ពីជើងមួក ។

• **ថ្នាក់ប្រធានប៉ុស្តិ៍ :**

មានរូបភាព និងម៉ូតដូចថ្នាក់ការិយាល័យ និងសាខាដែរ តែខុសគ្នាត្រង់ផ្នែកខាងមុខ លើកណ្តាប់វីណ្ណមានភ្ជាប់រូបព្រះសង្ខាពណ៌ប្រាក់ និងផ្នែកខាងមុខក្រោមកណ្តាប់វីណ្ណ ដែលនៅពីលើក្បាំងមួកមាន កម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅចុងខ្សែទាំងសងខាង ភ្ជាប់ដោយឡេវរូបព្រះសង្ខាពណ៌ប្រាក់ នៅលើក្បាំងមួក មានឆ្នូតពណ៌ប្រាក់ ដល់ជើងមួក ។

• **ថ្នាក់មន្ត្រីភ្នាក់ងារ :**

មានរូបភាព និងម៉ូតដូចថ្នាក់ប្រធានប៉ុស្តិ៍ដែរ ខុសគ្នាត្រង់នៅលើក្បាំងមួក គ្មានឆ្នូតពណ៌ប្រាក់ទេ ។

ឯកសណ្ឋានដូចបានរៀបរាប់ខាងលើ សម្រាប់ស្លៀកពាក់ធ្វើការក្នុងការិយាល័យ និងចុះបំពេញបេសកកម្មការងារ ឬទាក់ទងស្ថាប័ននានាក្នុងប្រទេស ។

រូបគំរូនៃឯកសណ្ឋាន ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ សាខា និងថ្នាក់មន្ត្រីភ្នាក់ងារ **មានដូចក្នុង ឧបសម្ព័ន្ធទី ១ ទី២ និង ទី៣ ។**

**ខ-ផ្លាកសញ្ញាសំគាល់ :**

ផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ" កាំកុងត្រូល" ត្រូវបានកំណត់ដូចខាងក្រោម ÷

សញ្ញា កាំកុងត្រូល មានរាងពងក្រពើ ។

➢ ផ្ទៃខាងក្នុងមាន :

- រូបប្រាសាទកំពូល ៣ តំណាងអោយព្រះរាជាណាចក្រកម្ពុជា
- រូបផែនទីសកលលោក តំណាងអោយទ្វីប សហគមន៍ ឬតំបន់ទំនាក់ទំនងលើកិច្ចការត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ ។
- រូបជញ្ជីង តំណាងអោយអាជ្ញាកណ្តាល ឯករាជ្យ អព្យាក្រឹត្យ និង យុត្តិធម៌
- រូបកែវ ពង្រីក (ពណ៌ ស នៅចំកណ្តាល បញ្ឈិតជញ្ជីង) តំណាងអោយការងារត្រួតពិនិត្យគុណភាព បង្ក្រាបការក្លែងបន្លំគុណភាពទំនិញ គម្មសិទ្ធិបញ្ញា និងសុវត្ថិភាព ម្ហូបអាហារទីផ្សារពាណិជ្ជកម្ម ។

➢ នៅរង្វង់ខាងក្រៅ រូបខាងលើ : មានអក្សរពណ៌ ទឹកប៊ិច ដាក់ថា ព្រះរាជាណាចក្រកម្ពុជា

➢ នៅរង្វង់ខាងក្រៅ រូបខាងក្រោម : មានអក្សរពណ៌ ទឹកប៊ិច ដាក់ថា កាំកុងត្រូល ជាអក្សរខ្មែរ និងអក្សរឡាតាំង រូបគំរូផ្លាកសញ្ញាសំគាល់ មានដូចក្នុង ឧបសម្ព័ន្ធទី ៤ ។

ផ្លាកសញ្ញាសំគាល់ដាក់លើសញ្ញាសក្តិលើស្មា សម្រាប់ពាក់លើចុងកអាវឆ្វេង ស្តាំ ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ សម្រាប់ដាក់ផ្លាកឈ្មោះ ។

**ក-ផ្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ**

កំណត់យកតាមផ្លាកសញ្ញាសំគាល់របស់នាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ដែលមានរាងមូលទំហំ ២.៣ ស.ម ធ្វើអំពីស្ពាន់ និង ក្រូមេ (សម្រាប់មន្ត្រី ភ្នាក់ងារ)

មានរូបភាពដូចផ្លាកសញ្ញាចុងកអាវ របស់មន្ត្រីភ្នាក់ងារដែរ តែត្រង់មានទំហំធំជាង គឺ ២.៥ ស.ម មានរាងប៉ោង មានទម្រង់ស្លឹកឈើចំនួនពីរមែកខ្វែងគ្នារំលេចដោយពណ៌មាសស្រោបកែវភ្លឺ (សម្រាប់ថ្នាក់ដឹកនាំ) ។

**ខ-ផ្លាកសញ្ញាកាំកុងត្រូលដេរភ្ជាប់លើដើមដៃអាវខាងស្តាំ**

កំណត់យកផ្លាករាងពងក្រពើ (ទំហំបន្ទាត់ផ្ចិត៨ស.ម ) ធ្វើអំពីសាច់ក្រណាត់ ដែលចាក់ដោយកំព្យូទ័រនិងអំបោះសូត្រ ។ ផ្ទៃខាងក្នុងពណ៌ផ្ទៃមេឃ ផ្នែកខាងក្រោមមានរូបជញ្ជីងពណ៌លឿង ។ ផ្នែកខាងលើមានបន្ទាត់ស្របនឹងខ្សែបន្ទាត់កាត់ទទឹងពណ៌ស ។ ផ្នែកខាងលើបង្អស់នៃផ្លាករាងពងក្រពើមានសរសេរអក្សរខ្មែរពណ៌លឿងទឹកប៊ិច " កាំកុងត្រូល " ។ ផ្នែកខាងក្រោមបង្អស់សរសេរអក្សរឡាតាំងពណ៌ខៀវទឹកប៊ិច " CAMCONTROL " ព័ទ្ធជុំវិញផ្លាករាងពងក្រពើ ដោយខ្សែបន្ទាត់ពណ៌លឿងបិទជិត ។

ទន្ទឹមនោះត្រូវមានផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម និង ផ្លាកសញ្ញាសំគាល់មន្ត្រី កាំកុងត្រូល :

**ក-ផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម**

ផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម មានរូបសញ្ញារបស់ក្រសួងពាណិជ្ជកម្ម ដែលរំលេចដោយរូបភាព និងពណ៌ប្រចាំក្រសួង មានរាងមូលប៉ោងទំហំ ៤.៧ ស.ម ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំ ។

**ខ-ផ្លាកសំគាល់ឈ្មោះមន្ត្រី**

កំណត់យកផ្លាករាងបួនជ្រុងទ្រវែង ទំហំបណ្តោយ ១០ ស.ម ទទឹង ២ស.ម ធ្វើអំពីជាតិជ័ររឹង ។ ផ្ទៃខាងក្នុងពណ៌ខៀវទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ស បិទជិត។ ផ្នែកខាងលើសរសេរឈ្មោះមន្ត្រីរាជការជាអក្សរខ្មែរ ។ ផ្នែកខាងក្រោមសរសេរអត្តលេខមន្ត្រី រាជការជាអក្សរឡាតាំង ។

**៣-សញ្ញាសក្តិស្មា** ៖ ខ្នាតសញ្ញាសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម :

-បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ

-បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាម៉ុទាល

សញ្ញាសក្តិស្មាត្រូវបានរៀបចំដោយឡែកជា៥ថ្នាក់ ខុសៗគ្នា សម្រាប់សំគាល់ថ្នាក់ប្រធាននាយកដ្ឋាន សម្រាប់សំគាល់ថ្នាក់អនុប្រធាននាយកដ្ឋាន សម្រាប់ថ្នាក់ប្រធាន

ការិយាល័យ និងថ្នាក់ប្រធានសាខា សម្រាប់ថ្នាក់អនុប្រធានការិយាល័យ និងថ្នាក់អនុប្រធានសាខា និង សម្រាប់ថ្នាក់មន្ត្រីភ្នាក់ងារ ។

**ក-សម្រាប់ថ្នាក់ប្រធាននាយកដ្ឋាន :**

មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្គស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រួល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រួល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាសមួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ បី ខ្សែ ពណ៌មាស ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិប្រធាននាយកដ្ឋាន មានដូចក្នុង ឧបសម្ព័ន្ធទី ៥ ។**

**ខ-សម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន :**

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្គស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រួល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រួល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាស មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ ពីរ ខ្សែ ពណ៌មាស ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិអនុប្រធាននាយកដ្ឋាន មានដូចក្នុង ឧបសម្ព័ន្ធទី ៦ ។**

**គ-សម្រាប់ថ្នាក់ប្រធានការិយាល័យ និង ប្រធានសាខា :**

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្គស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រួល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រួល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាស មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយ ខ្សែ ពណ៌មាស ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិ ប្រធានការិយាល័យ ប្រធានសាខា មានដូចក្នុង ឧបសម្ព័ន្ធទី ៧ ។**

**ឃ-សម្រាប់ថ្នាក់អនុប្រធានការិយាល័យ និង អនុប្រធានសាខា :**

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្គស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រួល ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាកាំកុងត្រួល ពណ៌ប្រាក់ ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌ប្រាក់ មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយខ្សែ ពណ៌មាស ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិ អនុប្រធានការិយាល័យ អនុប្រធានសាខា មានដូចក្នុង ឧបសម្ព័ន្ធទី ៨ ។**

**ង-សម្រាប់ថ្នាក់មន្ត្រីភ្នាក់ងារ :**

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្គស់ មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ នៅលើក្បាច់នេះមានអក្សរ កាំកុងត្រួល ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាកាំកុងត្រួល ពណ៌ប្រាក់ ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌ប្រាក់ មួយ មានក្បាច់ភ្ញីទេស ពណ៌ប្រាក់ ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយ ខ្សែ ពណ៌ប្រាក់ ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិមន្ត្រីភ្នាក់ងារ មានដូចក្នុង ឧបសម្ព័ន្ធទី ៩ ។**

**មាត្រា ៣.-**

ក្នុងពេលប្រតិបត្តិការ មន្ត្រីរាជការកាំកុងត្រូលទាំងពីរភេទ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និងពាក់ផ្លាកសញ្ញាសំគាល់ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ជាប់តាមខ្លួនផង ។ ក្នុងពិធីប្រជុំ ឬពិធីផ្សេងៗទៀត បើចាំបាច់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសំគាល់ផងដែរ ។

**មាត្រា ៤.-**

ជនក្លែងបន្លំខ្លួន ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និង សញ្ញាសំគាល់ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៥.-**

អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្ដីពីឯកសណ្ឋាន សញ្ញាសក្ដិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## ឯកសណ្ឋានសម្រាប់ ប្រធាន-អនុប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី ២

## នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
## ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
## ទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## ឯកសណ្ឋានសម្រាប់ ប្រធាន-អនុប្រធានការិយាល័យ



## ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

### ឯកសណ្ឋានសម្រាប់ ធ្លាក់ខារ



# ឧបសម្ព័ន្ធទី ៤

## អនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥
## ស្ដីពីឯកសណ្ឋាន សញ្ញាសក្ដិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហាំណូ-អាហាំណូ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"

## ផ្លាកសញ្ញាសំគាល់របស់
## នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហាំណូ-អាហាំណូ និងបង្ក្រាបការក្លែងបន្លំ

# ឧបសម្ព័ន្ធទី ៥

នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## សញ្ញាសក្តិសម្រាប់ ប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី ៦

នៃអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរំណ-អាហរំណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## សញ្ញាសក្តិសម្រាប់ អនុប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី ៧

នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## សញ្ញាសក្តិសម្រាប់ ប្រធានការិយាល័យ និងប្រធានសាខា



# ឧបសម្ព័ន្ធទី ៨

នៃអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## សញ្ញាសក្តិសម្រាប់ អនុប្រធានការិយាល័យ និងអនុប្រធានសាខា



# ឧបសម្ព័ន្ធទី ៩

នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្ដីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍_អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## សញ្ញាសក្តិសម្រាប់ ធ្លាក់ខារ

